# ការធានាឱ្យបានសំណាបថ្លោសល្អសំរាប់យកទៅស្ទូង

Farmer Magazine, May 2010



ដើម្បីឱ្យស្រូវរបស់លោកអ្នកលូតលាស់បានល្អ នាំមកនូវផលខ្ពស់ សំណាបថ្លោសល្អជាកត្តាសំខាន់មួយ. ដើម្បីឱ្យទទួលបានសំណាបថ្លោសល្អ យើងខ្ញុំសូមណែនាំ ឱ្យលោកអ្នកសាកល្បងអនុវត្តតាមបច្ចេកទេស ទាំង ៩ ដូចខាងក្រោមនេះ :

១. រើសយកតែគ្រាប់ពេញសុទ្ធល្អទៅសាប ដោយរើសចេញនូវគ្រាប់ដែលមានពណ៌ និងរាងខុសធម្មតាចោល. លោកអ្នកអាចត្រូវចំណាយពេលច្រើនបន្តិចមែន តែការប្រើពូជសុទ្ធល្អនាំឱ្យលោកអ្នកទទួលបានផលច្រើន ហើយលក់ស្រូវបានតម្លៃថ្លៃទៀតផង ។

២. យកគ្រាប់ដែលរើសហើយទៅត្រាំជាមួយទឹកមានជាតិស្ងោ (ទឹកដែលត្រាំជាមួយគ្រាប់ សំបក ឬស្លឹកស្ងោ) ដើម្បីជួយការពារគ្រាប់ពីការបំផ្លាញពីសត្វល្អិតផ្សេងៗ ។

៣. រៀបចំថ្នាលសំណាបគោក ដូចរងស្លែ ដើម្បីជៀសវាងកុំឱ្យសំណាបលិចទឹក ដែលនាំឱ្យវាលូតរាងវែង (លូតតែកំពស់ តែមិនសូវរឹកទទឹង) ។

៤. ប្រើជីកំប៉ុស្ត ឬដីមមោកព្រៃ (ដីស្រទាប់លើនៅក្នុងព្រៃ) ឬគុម្ពោតព្រៃឱ្យបានច្រើន. ជីកំប៉ុស្តនាំឱ្យដីផុស ហើយសើមបានល្អ ដែលអំណោយផលដល់ការលូតលាស់របស់សំណាប ។

៥. សាបស្តើងជាងធម្មតា ដើម្បីឱ្យដើមសំណាបនិមួយៗដុះរីកមាឌទទឹងបានល្អ (សំណាបថ្លោស).

៦. ក្រោយពេលសាបហើយ គ្របដីដោយប្រើស្លឹកឈើ (ប្រើទាំងស្លឹកទាំងមែក) ហើយដកស្លឹកឈើចេញពេលសំណាបចាប់ផ្តើមដុះ ។

៧. ដកសំណាបនៅកន្លែងដែលចង្អៀតពេកចេញខ្លះ ។

៨. ស្រោចទឹកបន្ថែម ប្រៀបដូចស្រោចកូនស្លែ ក្នុងករណីអត់មានភ្លៀង. គេគួរលាយទឹកជាមួយទឹកនោមគោក្នុងបរិមាណ ១:១០ (ទឹកនោមដែលទុកឱ្យកាច់បានជាង ៧ ថ្ងៃ) ដើម្បីជំរុញការលូតលាស់បន្ថែម ។

៩. នៅពេលដកសំណាបទៅស្ទូង ដកតែដើមសំណាបថ្លោសជាងគេទៅស្ទូងបានហើយ ។

ក្នុងចំណោមបច្ចេកទេសទាំង ៩ ខាងលើនេះ លោកអ្នកអាចជ្រើសរើសមួយណាអនុវត្តក៏បានដែរ តែការផ្គុំចូលគ្នាបានច្រើនចំណុច នាំមកនូវផលល្អជាងការអនុវត្តបានតិចចំណុច ។ ក្នុងករណីយ៉ាងណាក៏ដោយក៏លោកអ្នកគួរអនុវត្តឱ្យបាននូវចំណុចទី ១ និងទី ៩ គឺរើសតែគ្រាប់ល្អទៅសាប និងសំណាបថ្លោសទៅស្ទូង ។

**បណ្ឌិត យ៉ង សាំងកុមារ**